# រឿង ឃាយបីពាំនួត

គូរដោយៈ គាំ សាម៉ែន



# រឿង បាយបីពំនូត

និពន្ធដោយ អ្នកស្រី ឱម ធិរិទ្ធ

គូររូបដោយ លោក គាំ សារ៉ែន

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០២

# បុព្វកថា

******

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារនេះ បានរៀបរៀងឡើងក្នុងគោលបំណងៈ

- ធ្វើអោយកុមារមានសេចក្តីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- អោយកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជួយដល់ឪពុកម្តាយ រឺលោកគ្រូ អ្នកគ្រូ ក្នុងការនិទានរឿងសំរាប់កុមារ

យើងខ្ញុំរង់ចាំទទួលនូវការផ្តល់មតិកែលំអពីមិត្តអ្នកអានទាំងអស់ដោយសេចក្តីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ



កាលពីព្រេងនាយ មានប្តីប្រពន្ធពីរនាក់រស់នៅក្បែរជើងភ្នំមួយ ។ គ្រួសារនោះក្រីក្រណាស់ តែឧស្សាហ៍ព្យាយាម ចេះអត់ធ្មត់តស៊ូ ស្លូតបូត គួរជាទីរាប់អាននៃអ្នកស្រុកទាំងឡាយ ។





រាល់ថ្ងៃ  បុរសជាប្ដីតែងតែទៅកាប់គាស់រានព្រៃធ្វើ ចំការដាំដំណាំចិញ្ចឹមជីវិត ។  តែដំណាំមិនបានផលសោះ ។ ដោយទីទ័លក្រ ប្រពន្ធចៅកំសត់ មានតែបាយបីពំនូត និងអំបិលវេចអោយប្ដីយកទៅហូបនៅឯព្រៃ ។





បុរសកំសត់ខំប្រឹងធ្វើការក្រោមកំដៅដែលថែងចាំង យ៉ាងខ្លាំង ដោយគ្មានត្អូញត្អែរ ។ ថ្ងៃកាន់តែជ្រេ ឯពោះកាន់តែឃ្លាន បុរសនោះក៏ឈប់សំរាកក្រោមម្លប់ឈើមួយដើមដើម្បីបរិភោគបាយ ។





ដោយឃ្លានពេក  បុរសកំសត់លាកញ្ចប់បាយដោយដៃទាំងពីរញ័រទទ្រើក ។ ស្រាប់តែបាយមួយពំនូតជ្រុះពីដៃ  ហើយរមៀលច្រើនត្រលប់នៅលើស្មៅ  ។ បុរសស្តាយបាយណាស់ ក៏រត់ដេញតាមពំនូតបាយផង ស្រែកផងថា «ឈប់ ! បាយ !  បាយពំនូត សុំកុំទៅណា !» ។



ពំនូតបាយរមៀលកាន់តែលឿនទៅ ៗ ហើយធ្លាក់ចូលទៅក្នុងរូងមួយបាត់ ។



បុរសកំសត់ឃ្លានផង ឆ្ងល់ផង ខំប្រឹងឈ្ងោកមើលរូង ងងឹតទាំងសោកស្តាយ ។ រំពេចនោះ សំលេងភ្លេង មហោរីបានលាន់រងំយ៉ាងពីរោះលន្លង់លន្លោចចេញមក ពីរូងចំលែកនោះ ។ បុរសកំសត់លឺភ្លេងហើយ រំភើប សប្បាយរីករាយ ភ្លេចបាត់អស់នូវក្តីនឿយហត់ស្រេក ឃ្លានទាំងប៉ុន្មាន ។



បុរសកំសត់ងឿងឆ្ងល់លាន់មាត់ថា «តើសំលេងភ្លេង
មហោរីដ៏ពីរោះលេងនៅទីណា? លាន់ចេញពីទីកន្លែង
ណាមក?» ។



ចង់ដឹងពេក គាត់ក៏យកបាយមួយពំនូត ទៀតទម្លាក់ទៅក្នុងរូងចំលែកនោះ ។ បន្ទាប់មកបទភ្លេង មហោរីក៏លាន់លឺឡើងពីរោះរងំអង្រួនដួងចិត្តបុរស កំសត់អោយភ្លឹកអារម្មណ៍ ភ្លេចទុក្ខកង្វល់ បាត់ការ ស្រេកឃ្លាន ស្រមៃឃើញតែភាពសប្បាយ ភាពរុងរឿង ដ៏សុខសាន្ត ។





ដោយក្ដីសុខដុមរមនាក្នុងចិត្ត បុរសកំសត់ក៏យកពំនូតបាយទីបីបោះចូលទៅក្នុងរូងម្ដងទៀត ។ ភ្លេងមហោរីក៏បន្លឺឡើងម្ដងទៀត ធ្វើអោយបុរសមានអារម្មណ៍រំភើបរីករាយ រាំផងច្រៀងផង តាមសំលេងភ្លេងដែលរសាត់ឆ្ងាយទៅ ៗ រហូតដល់គាត់ភ្លេចខ្លួន ក៏រអិលជើងធ្លាក់ចូលក្នុងរូងនោះ ហើយសន្លប់បាត់ស្មារតី ។





លុះភ្ញាក់ខ្លួនឡើង គាត់ឃើញកណ្ដុរសជាច្រើន នៅជុំវិញខ្លួន ។ បុរសនោះភ្ញាក់ផ្អើលយ៉ាងខ្លាំង ប្រុងស្ទុះរត់ តែកណ្ដុរសទាំងនោះស្រែកឡើងថា «សូមស្វាគមន៍លោកម្ចាស់ ! អញ្ជើញលោកម្ចាស់បរិភោគចំណីអាហារដែលរៀបជាស្រេចនេះចុះ» ។ បុរសគិតថា «នេះជាអាហាររបស់គេ បើអញហូបអស់ទៅ តើពួកគេនឹងបានអ្វីហូប ?» ។





គិតហើយ គាត់បរិភោគតែបន្តិចអោយសមល្មមនឹងបាយបីពំនូតដែលគាត់ធ្លាប់ហូបរាល់ថ្ងៃ ។ ពេលនោះស្តេចកណ្តុរសក៏មកដល់ ហើយនិយាយថា « ហៃបុរសកំសត់ ! អ្នកជាមនុស្សទៀងត្រង់មានធម៌មេត្តា ចិត្តល្អមិនលោភលន់ មិនចង់បានរបស់គេហួសពេក ។ យើងជូនស្គរទិព្វនេះដល់អ្នកចុះ ។ ស្គរនេះប្រើបានតែបីដងទេសូមអ្នកយកវាទៅប្រើក្នុងផ្លូវល្អចិញ្ចឹមជីវិត និងមានប្រយោជន៍ដល់មនុស្សជាតិទាំងឡាយផង » ។





បានស្គរហើយ បុរសកំសត់ក៏លាស្ដេចកណ្ដុរសមកផ្ទះវិញ  គាត់រៀបរាប់ប្រាប់ប្រពន្ធពីរឿងដែលខ្លួនបានជួបនឹងកណ្ដុរស ។ ស្អែកឡើង  បុរសកំសត់បួងសួងក្នុងចិត្តយ៉ាងយូរ រួចគោះស្គរឡើង  ។  រំពេចនោះ សំលេងភ្លេងមហោរីលាន់លឺយ៉ាងពីរោះ ។  បុរសកំសត់សប្បាយចិត្តណាស់  ព្រោះឃើញចំការរបស់ខ្លួន  មានដំណាំគ្រប់មុខដុះឡើង ដោយមានផ្លែផ្កាពាសពេញដើម ។ ប្ដីប្រពន្ធពីរនាក់ប្រមូលផលយកទៅលក់បានកំរៃយ៉ាងច្រើន ។





ថ្ងៃក្រោយមកទៀត បុរសក៏យកស្គរមកគោះជាលើកទីពីរ ដោយបួងសួងសុំគ្រាប់ពូជគ្រប់មុខ ចែកចាយដល់អ្នកស្រុកទាំងឡាយនៅក្នុងភូមិ ។ អ្នកស្រុកយកគ្រាប់ពូជទាំងនោះ ទៅដាំក្នុងពេលតែមួយថ្ងៃដំណាំទាំងនោះរីកលូតលាស់ល្អបានផ្កាផ្លែយ៉ាងឆាប់រហ័ស ។ ប្រជាជនរីករាយប្រមូលផលយកទៅលក់ដូរ សឹងក្លាយជាអ្នកមានគ្រប់ៗ គ្នា ។



ចាប់ពីថ្ងៃនោះមក ប្ដីប្រពន្ធទាំងពីរនាក់រស់នៅយ៉ាង
សុខសប្បាយ ប៉ុន្តែគ្មានកូនមួយសោះ ។ គាត់នឹកឃើញ



ចង់បានកូន ក៏បួងសួងដល់សួគ៌ទិព្វសុំកូន ហើយក៏គោះស្គរឡើង។ ភ្លេងមហោរីក៏បន្លឺឡើងយ៉ាងពីរោះ។ ភ្លាមនោះសំលេងកូនង៉ែតពីរនាក់ក៏យំព្រមគ្នាដែរ ។ បុរសកំសត់ និង ភរិយាត្រេកអររកអ្វីប្រដូចគ្មាន។ គាត់បំរុងរត់ទៅលើកកូនង៉ែតទាំងពីរនោះ ស្រាប់តែពួកគេធំឡើងយ៉ាងរហ័ស ចេះញញឹម ហើយរត់មករកគាត់ ៕

៙ចប់៚



560016

